**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សំណុំរឿងរដ្ឋប្បវេណីលេខៈ ៦៣៣
ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨
សាលក្រមលេខ ១៣៥ (ជ)
ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៩

**សាលក្រម**
**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ស្ពឺ**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

-រវាងដើមចោទឈ្មោះ [redacted] អួន ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរដើររោងការ មានទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ដោយមានលោកមេធាវី [redacted] តំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] ឈៀង ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរដើររោងការ មានទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ដោយមានលោកមេធាវី [redacted] លោកស្រីមេធាវី [redacted] លោក [redacted] តំណាងដោយអាណត្តិ ។

## **១.អង្គហេតុ និងចំណុចវិវាទ**

**១.១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

-បញ្ចប់ការរួមរស់ជាអនីតិសង្វាស់ពីប្តីឈ្មោះ [redacted] ឈៀង អាយុ ៤៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ។

-ទុកសិទ្ធិឱ្យកូន២ជ្រើសរើសអំណាចមេបាគឺៈ

ក.ឈ្មោះ [redacted] សូលីន ភេទប្រុស អាយុ ១៧ឆ្នាំ

ខ.ឈ្មោះ [redacted] សៀវមិញ ភេទស្រី អាយុ ១៤ឆ្នាំ

-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាមានដូចជាៈ

ក.ដីលំនៅដ្ឋាន (ទទឹង១៥ម៉ែត្រ គុណ បណ្តោយ៥០ម៉ែត្រ) មានលិខិតបញ្ជាក់ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ស្ថិតនៅភូមិត្រពាំងថ្ម ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ខ.ដីស្រែចំនួន ០២កន្លែង ស្ថិតនៅភូមិត្រពាំងថ្ម ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

គ.សម្ភារៈតុការ (សម្ភារៈតុការ, រោងការ, បាស១កំប្លេ, ម៉ាស៊ីនភ្លើង ០២គ្រឿង, គស់យ៉ាបផ្ទះដាក់ឥវ៉ាន់ និងឡាន, ឃ្លាំងដាក់ឥវ៉ាន់ ។



Scanned with CamScanner

ឃ.ឡានម៉ាក HYUNDAI (២តោនកន្លះ) ពាក់ស្លាកលេខ: ភព ៣A-៣០៦៣ ។

-សុំឱ្យទទួលស្គាល់បំណុលរួមម្នាក់ពាក់កណ្តាល

-បំណុលខ្ចីធនាគារ[redacted]ចំនួន ២៦,០០០ (ពីរម៉ឺនប្រាំមួយពាន់) ដុល្លារ ។

១.២.ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា កាលពីឆ្នាំ២០០២ ទៅតាមប្រពៃណី ប៉ុន្តែ មិន បាន ចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធគឺមានរយៈពេល ១៦ឆ្នាំ មានកូនចំនួន ០២នាក់ ដែល កូនទី១ ឈ្មោះ [redacted] សូលីន ភេទប្រុស អាយុ ១៦ឆ្នាំ និងកូនទី២ឈ្មោះ [redacted] សៀវមិញ ភេទស្រី អាយុ ១៣ឆ្នាំ ហើយមាន ទ្រព្យសម្បត្តិរួម និងបំណុលរួមមួយចំនួនផងដែរ ។ នាពេលបច្ចុប្បន្នភាគីចុងចម្លើយឈ្មោះ [redacted] ឈៀង រស់នៅជាមួយ ភាគីដើមចោទឈ្មោះ[redacted]អួន មិនចុះសម្រុងនឹងគ្នាឈ្លោះទាស់ទែងស្ទើររាល់ថ្ងៃ ធ្លាប់តំរាម និងប្រើអំពើហិង្សាទៅលើដើម ចោទចំនួន ០២លើកមកហើយ និងធ្លាប់មានបណ្តឹងទៅសាលាឃុំចំនួន ០២ដងផងដែរ ។ ដូច្នេះធ្វើឱ្យដើមចោទអស់ មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ហើយបានដាក់ពាក្យប្តឹងសុំបញ្ឈប់ការរួមរស់នៅជាអនីតិសង្វាស់មកកាន់សាលាដំបូង ខេត្តកំពង់ស្ពឺ ។

១.៣.សេចក្តីថ្លែងការណ៍របស់គូភាគី ៖

*-ដើមចោទឈ្មោះ[redacted]អួន ដែលមានលោក[redacted]ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា ៖* ខ្លួន សូមរក្សាការទាមទារនៅក្នុងពាក្យបណ្តឹងដែលបានដាក់ចូលមកសាលាដំបូងខេត្តកំពង់ស្ពឺចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ សេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ និងនៅក្នុងសេចក្តីថ្លែង ការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើបណ្តឹងតប ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ទុកនៅដដែល ។ ចំពោះឥវ៉ាន់គុការ រួមជាមួយសម្ភារៈបម្រើឱ្យរោងការខាងចុងចម្លើយបានដឹកទៅទុកនៅឯផ្ទះបងស្រីរបស់គាត់ឈ្មោះ [redacted] និងប្តីឈ្មោះ [redacted] យឹម ចំនួន ០១ឡាន១តោនកន្លះពេញ ហើយបងស្រីបង្កើតរបស់ចុងចម្លើយក៏រកស៊ីខាងរោងការផងដែរ តែមិនដឹងថាមានចំនួនប៉ុន្មាននោះទេ ដែលការដឹកឥវ៉ាន់នេះគឺមុនពេលសុំចេញដីកាសម្រេចរក្សាការពារ ដែលគុមុនពេល ដឹកចេញគឺមានចំនួន ១១០គុ ហើយបច្ចុប្បន្ននៅសល់ ៧០គុ ។ ខ្លួនសូមសំណូមពរឱ្យតុលាការសម្រេចតាមការទាមទារ របស់ខ្លួន និងសុំឱ្យតុលាការពិនិត្យតាមភស្តុតាងដែលខ្លួនបានដាក់ចូលមកតុលាការ និងសុំឱ្យតុលាការចុះទៅពិនិត្យភស្តុ តាងដែលសាច់ញាតិចុងចម្លើយបានលួចដឹកចេញឱ្យស្របទៅតាមការស្នើសុំពិនិត្យភស្តុតាងរបស់ចុងចម្លើយ ។

*-ចុងចម្លើយឈ្មោះ [redacted] ឈៀង ដែលមានលោកមេធាវី [redacted] លោកស្រីមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ ថា ៖* ខ្លួនសូមរក្សាការទាមទារនៅក្នុងពាក្យបណ្តឹងតបដែលបានដាក់ចូលមកសាលាដំបូងខេត្តកំពង់ស្ពឺ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ សេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ និងនៅ ក្នុងសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើបណ្តឹងតប ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ទុកនៅដដែល ។ ចំពោះចំណុចខាងលើដែលដើមចោទបានបញ្ជាក់ថាខ្លួនលួចដឹកគុចេញទៅទុកនៅឯផ្ទះបងស្រីរបស់ខ្លួន ឈ្មោះ [redacted] និងប្តីឈ្មោះ [redacted] យឹម ចំនួន ០១ឡាន១តោនកន្លះពេញ នោះគឺមិនពិតនោះទេ ខ្លួនសូមឱ្យខាងដើមចោទដា ក់ភស្តុតាងដើម្បីពិនិត្យ ។ ខ្លួនសូមសំណូមពរឱ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួន និងសុំឱ្យតុលាការពិនិត្យ តាមភស្តុតាងដែលខ្លួនបានដាក់ចូលមកតុលាការ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ ។ ខ្លួនសូមដាក់បញ្ចូលភស្តុតាង ដោយផ្ទាល់នាពេលទាញហេតុផលដោយផ្ទាល់មាត់នូវរូបថតគុការ សម្ភារៈរោងការចំនួន ១២សន្លឹក រួមជាមួយឯកសាររាយ

បញ្ជីទាក់ទងនឹងផ្ទុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ០១សន្លឹក ហើយការបញ្ចូលភស្តុតាងនេះសាក្សីខាងដើមចោទក៏ទទួលស្គាល់ដែរ ។

*-ដើមចោទឈ្មោះ* [redacted] *អូន ដែលមានលោក* [redacted] *ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា ៖* ខ្លួនសូមបដិសេធការដាក់បញ្ចូលភស្តុតាងដោយផ្ទាល់នាពេលទាញហេតុផលដោយផ្ទាល់មាត់នូវរូបថតតុការ សម្ភារៈរោងការចំនួន ១២សន្លឹក រួមជាមួយឯកសារោយបញ្ជីទាក់ទងនឹងផ្ទុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ០១សន្លឹក របស់ភាគីចុងចម្លើយ ។

*-ចុងចម្លើយឈ្មោះ* [redacted] *ឈៀង ដែលមានលោកមេធាវី* [redacted] *ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា ៖* ខ្លួនសូមបដិសេធការសុំរបស់ដើមចោទដែលសុំឱ្យតុលាការចុះទៅពិនិត្យភស្តុតាងដែលសាច់ញាតិខាងខ្លួនបានលួចដឹកចេញនោះ ខ្លួនសូមបដិសេធព្រោះនីតិវិធីនៃការពិនិត្យភស្តុតាងបានផុតពេលកំណត់របស់តុលាការទៅហើយ ។

+អំពីកូន

*-ឈ្មោះ* [redacted] *សូលីន ភេទ ប្រុស អាយុ ១៧ ឆ្នាំ បានថ្លែងការណ៍ថា ៖* ខ្លួនសូមសិទ្ធិទៅរស់នៅជាមួយឪពុក និងខ្លួនសូមបញ្ជាក់ថា តុការជាក់ស្តែងមានតែ ៧០តុទេ បើករណីម្តាយមិនជឿសូមឱ្យគាត់ទៅរាប់ផ្ទាល់ក៏បាន ។

*-ឈ្មោះ* [redacted] *សៀវម៉ិញ ភេទ ស្រី អាយុ ១៤ ឆ្នាំ បានថ្លែងការណ៍ថា ៖* ខ្លួនសូមសិទ្ធិទៅរស់នៅជាមួយម្តាយ ។

*-សាក្សីឈ្មោះ* [redacted] *រ៉ៃ បានឆ្លើយបញ្ជាក់ថា ៖* ខ្លួនបានដឹងថា តុធ្លាប់មាន ១១០តុ ក្នុងនោះគុណភាពថ្មីប្រហែល ៦០តុ ហើយតុចាស់អាចជួសជុលបានមានប្រហែល ៤០ % សម្ភារៈតុការខ្លួនជាអ្នកដើរការ ដូចនេះគ្មាននរណាដឹងជាងខ្លួននោះទេ ។

*-សាក្សីឈ្មោះ* [redacted] *ភិន់ បានឆ្លើយបញ្ជាក់ថា ៖* ខ្លួនបានដឹងថា ខ្លួនជាអ្នករាប់ចានឆ្នាំងដែលបម្រើឱ្យរោងការរបស់គូភាគី ដែលមានចានឆ្នាំង បែកបាក់ខ្លះ និងទិញចូលថែមជាបន្តបន្ទាប់ខ្លះ ។

*-សាក្សីឈ្មោះ* [redacted] *រម៉ៅ បានឆ្លើយបញ្ជាក់ថា ៖* ខ្លួនបានដឹងថា នៅក្នុងការរកស៊ីដើររោងការរបស់គូភាគី ខ្លួនគឺជាអ្នកសាងសង់ជួសជុលឆ្អឹងដែករោងការ និងធ្វើសំយ៉ាតដាក់រថយន្ត និងសម្ភារៈតុការ ។

<u>ក្រោយពីតុលាការបានធ្វើការផ្សះផ្សារគូភាគីបានព្រមព្រៀងគ្នាដូចខាងក្រោម៖</u>

១. តុចំនួន ៣៥តុ, មានចានចង្កឹះចំនួន ៣៥០, ស្លាបព្រាចំនួន ៣៥០, កែវចំនួន ៣៥០, វែកបាយចំនួន ១០, វែកសម្លចំនួន ១០, ចាសដាក់ល្ងោយចំនួន ១០, ចាសលើកម្ហូបចំនួន ១០, ចានគ្រោងចំនួន ៣០, ចានញាំចំនួន ៣៥, ចានពងក្រពើចំនួន ៧០, ចានគ្រឿងក្លែមចំនួន ១៧៥, ចានទ្រនាប់ចំនួន ៣៥០, ឆ្នាំងបាយចំនួន ១០, ខ្ទះលេខ៨៥០ចំនួន ៦, កាធុនតូច និងធំចំនួន ២៥, តុវិលចំនួន ៣៥, ឆ្នាំងភ្លើងចំនួន ៣៥, ស្រោមកៅអី ៣៥០, រនាំងបាំងឡប់ឡៃពាក់កណ្តាលម្នាក់រាប់ជាក់ស្តែង, ធុងទឹកកកឱ្យអា២០០លីត្រចំនួន ០២, ឱ្យទៅដើមចោទ ។

២. រោង ០៤ខ្នង ឱ្យទៅដើមចោទ

៣. ធុងបាស់ ០១ឈុត ចែកជាពីរ

៤. បំណុលខ្ចីធនាគារ [redacted] ស៊ីចំនួន ២៣,៤០០ (ពីរម៉ឺនបីពាន់បួនរយ) ដុល្លារ សុំទទួលស្គាល់សងធនាគារចំនួនម្នាក់ពាក់កណ្តាល ។

៥. មេក្រូចំនួន ០៤ ចែកជាពីរ



Scanned with CamScanner

៦. ម៉ាស៊ីនភ្លើងមានចំនួន ០២ ចែកគ្នាម្នាក់មួយ ។

៧. សុំឱ្យដើមចោទប្រគល់កាតគ្រីឡានចំនួន ០២ និងពែកមីឡានខ្ញុំ ០១ និងកាតគ្រីម៉ូតូ ០១ ។

១.៤.ចំណុចវិវាទ

- គ្មាន

## ការពិនិត្យភស្តុតាង

*+ ភស្តុតាងរបស់ភាគីដើមចោទឈ្មោះ [redacted] អូន មានដូចជា:*

-សៀវភៅស្នាក់នៅលេខ ១៤៣ ក.ស្ត ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ឈៀង ។

-អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០៥៨៧៨០៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] អូន

-សំបុត្របញ្ជាក់កំណើតលេខ ៣៨ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] សូលីន ។

-សំបុត្របញ្ជាក់កំណើតលេខ ៥៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សៀវមិញ ។

-ប័ណ្ណសម្គាល់យានយន្តលេខ ភព ៣A-៣០៦៣ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] គួង និងឈ្មោះ [redacted] អូន ។

-លិខិតបញ្ជាក់ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ស្ថិតនៅភូមិត្រពាំងថ្ម ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជារបស់ឈ្មោះ [redacted] ឈៀង និងឈ្មោះ [redacted] អូន ។

-បញ្ជីខ្ទីប្រាក់ធនាគារ [redacted] ភីអិលស៊ី ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] ឈៀង ។

-បញ្ជីខ្ទីប្រាក់ធនាគារ [redacted] ភីអិលស៊ី ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ឈៀង ។

*+ ភស្តុតាងរបស់ភាគីចុងចម្លើយឈ្មោះ [redacted] ឈៀង មានដូចជា:*

-បង្កាន់ដៃទទួលពាក្យលេខ ១០៧៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩២ ០១ សន្លឹក (ថតចម្លង) ។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២ មានឈ្មោះ [redacted] ហាង និងប្រពន្ធឈ្មោះ [redacted] យ៉េក ជាម្ចាស់កម្មសិទ្ធិ ០១ច្បាប់ (ថតចម្លង) ។

-បង្កាន់ដៃទទួលពាក្យលេខ ១០៧៨ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩២ ០១សន្លឹក (ថតចម្លង) ។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ មានឈ្មោះ [redacted] ហាង និងប្រពន្ធឈ្មោះ [redacted] យ៉េក ជាម្ចាស់កម្មសិទ្ធិ ០១ច្បាប់ (ថតចម្លង) ។

-លិខិតបំភ្លឺលេខ ៣៩៣/១៩ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់លោក អូន ប៉េន ០១ច្បាប់ (ថតចម្លង) ។

-លិខិតបញ្ជាក់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ០១សន្លឹក (ថតចម្លង) ។

-សំបុត្រមរណភាពលេខ ០៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំស្រង់ បញ្ជាក់ថាឈ្មោះ [redacted] ហាង ស្លាប់ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៦ ០១ច្បាប់ (ថតចម្លង) ។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ លេខ០២៣/១៥ ស.ល ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ និងលេខ៣៦២/១៥ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ០១ច្បាប់ (ថតចម្លង) ។

-លិខិតផ្ទេរដីលំនៅដ្ឋាន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ របស់លោក [redacted] គួង និងឈ្មោះ [redacted] ឡាំងជូ និងគំនូសប្លង់ផ្ទះ ០៣ច្បាប់ (ថតចម្លង) ។

-តារាងបង់ប្រាក់របស់ធនាគារ [redacted] ០៥ច្បាប់ (ថតចម្លង) ។

-កំណត់ហេតុផ្សះផ្សារ និងសម្របសម្រួល ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨ ០៣សន្លឹក (ថតចម្លង) ។

-កំណត់ហេតុផ្សះផ្សារ និងសម្របសម្រួល ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ០៦សន្លឹក (ថតចម្លង) ។

-រូបថតបញ្ជាក់អំពីសម្ភារះភ្នង ០៤សន្លឹក ។

-រូបថតបញ្ជាក់អំពីដី និងផ្ទះនៅភូមិផ្សារស្លាបលែង ០២សន្លឹក (ថតចម្លង) ។

## ៣.សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

**៣.១.ស្តីពីការទាមទារទី១ ៖ សុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយ**

-តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ដែលបានអះអាងដូចគ្នាថា ពួកគេបានរៀបអាពាហ៍ពិពាហ៍នៅ ឆ្នាំ ២០០២ ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ ដូចនេះតាមមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍របស់អ្នកទាំងពីរត្រូវចាត់ទុកជាមោឃៈ ។

-ដើមចោទបានប្តឹងសុំឈប់រស់នៅជារអនីតិសង្វាសពីចុងចម្លើយ ដោយសំអាងថាការរស់នៅមិនចុះសម្រុងនឹងគ្នា ឈ្លោះទាស់ទែងស្ទើររាល់ថ្ងៃ ធ្លាប់គំរាម និងប្រើអំពើហិង្សាទៅលើដើមចោទចំនួន ០២លើកមកហើយ និងធ្លាប់មានបណ្តឹងទៅសាលាឃុំចំនួន ០២ដងផងដែរ ដូច្នេះធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ប៉ុន្តែតាមផ្លូវច្បាប់ បុគ្គលទាំងពីរនាក់ដែលបានរួមរស់ជាមួយគ្នាដូចជាប្តីប្រពន្ធ ដោយពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ ពុំមែនជាប្តីប្រពន្ធនឹងគ្នា តាមផ្លូវច្បាប់ទេ ។ ហេតុដូចនេះបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទ គឺជាបណ្តឹងមិនស្របច្បាប់ទេ ដែលតុលាការត្រូវលើកបណ្តឹងចោលតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ដើមចោទ និងចុងចម្លើយ មិនជាប់ចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាទៀតទេ ហេតុដូច្នេះ គូភាគីមានសិទ្ធិពេញលេញក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ហើយភាគីម្ខាងទៀតមិនមានសិទ្ធិជំទាស់អ្វីឡើយ ។

**៣.២.ស្តីពីការទាមទារទី២ ៖ ការសុំមានអំណាចមេបាលើកូន ក.ឈ្មោះ [redacted] សូលីន ភេទប្រុស អាយុ ១៧ឆ្នាំ ខ.ឈ្មោះ [redacted] សៀវមិញ ភេទស្រី អាយុ ១៤ឆ្នាំ**

-ក្នុងការរួមរស់ជាមួយគ្នា គូភាគីបានអះអាងថាមានកូនចំនួន ០២នាក់ ដែលមិនទាន់ពេញនីតិភាព ដែលកូនទី១ឈ្មោះ [redacted] សូលីន កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រង់ និងកូនទី២ឈ្មោះ [redacted] សៀវមិញ កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រង់ ។

-ចំពោះកូនទាំងពីរនាក់ កូនទី១ឈ្មោះ [redacted] សូលីន កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០២ សុំសិទ្ធិទៅរស់ជាមួយឪពុក (ចុងចម្លើយ) និងកូនទី២ឈ្មោះ [redacted] សៀវមិញ កើតថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៥ សុំសិទ្ធិទៅរស់ជាមួយម្តាយ (ដើមចោទ) និងគូភាគីបានទុកសិទ្ធិឱ្យកូនជ្រើសរើសអំណាចមេបា គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា ១០៣៧ ចំណុចទី១ នៃក្រមរដ្ឋប្បវេណី ។

**៣.៣.ស្តីពីការទាមទារទី៣ ៖ អំពីការបែងចែកទ្រព្យសម្បត្តិរួម**

-តាមការអះអាងរបស់គូភាគី បានព្រមព្រៀងគ្នាបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម ៖

១. តុចំនួន ៣៥តុ, មានចានចង្កឹះចំនួន ៣៥០, ស្លាបព្រាចំនួន ៣៥០, កែវចំនួន ៣៥០, វែកបាយចំនួន ១០, វែកសម្លចំនួន ១០, ថាសដាក់ល្បោយចំនួន ១០, ថាសលើកម្ហូបចំនួន ១០, ចានគ្រោងចំនួន ៣០, ចានញាំចំនួន ៣៥, ចានពងក្រពើចំនួន ៧០, ចានគ្រឿងថ្លែមចំនួន ១៧៥, ចានទ្រនាប់ចំនួន ៣៥០, ឆ្នាំងបាយចំនួន ១០, ខ្ទះលេខ៥០ចំនួន ៦,

កាធុនតូច និងធំចំនួន ២៥, តុរិលចំនួន ៣៥, ឆ្នាំងភ្លើងចំនួន ៣៥, ស្រោមកៅអី ៣៥០, រនាំងបាំងឡប់ឡែពាក់កណ្ដាល ម្នាក់រាប់ជាក់ស្ដែង, ធុងទឹកកកឱ្យអា២០០លីត្រចំនួន ០២, ឱ្យទៅដើមចោទ ។

២. រោង ០៤ខ្នង ឱ្យទៅដើមចោទ

៣. ធុងបាស់ ០១ឈុត ចែកជាពីរ

៤. បំណុលខ្ចីធនាគា[redacted] ភីអិលស៊ីចំនួន ២៣,៤០០ (ពីរម៉ឺនបីពាន់បួនរយ) ដុល្លារ សុំទទួលស្គាល់សង ធនាគារចំនួនម្នាក់ពាក់កណ្ដាល ។

៥. មេក្រូចំនួន ០៤ ចែកជាពីរ

៦. ម៉ាស៊ីនភ្លើងមានចំនួន ០២ ចែកគ្នាម្នាក់មួយ ។

៧. សុំឱ្យដើមចោទប្រគល់កាតត្រីឡានចំនួន ០២ និងពែកមីឡានខ្ញុំ ០១ និងកាតត្រីម៉ូតូ ០១ ។ ហេតុនេះគប្បី តុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ។

**៣.៤.ស្ដីពីការទាមទារទី៤ ៖ បំណុលរួម**

-បំណុលខ្ចីធនាគា[redacted]ភីអិលស៊ីចំនួន ២៣,៤០០ (ពីរម៉ឺនបីពាន់បួនរយ) ដុល្លារ រួមទាំងអត្រាការប្រាក់ ។ ចំពោះបំណុលនេះ គូភាគីទទួលស្គាល់ថាជាបំណុលរួមពិតមែន ហេតុនេះគប្បីឱ្យគូភាគីទទួលបន្ទុកម្នាក់ពាក់កណ្ដាល ។

៣.៥. តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីម្នាក់ពាក់កណ្ដាល ។

## ៤.សេចក្ដីសម្រេចបញ្ចប់

៤.១. លើកចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] អូន ដែលបានដាក់ចូលមកសាលាដំបូង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ត្រង់ចំណុចប្ដឹងសុំបែកលំនៅដ្ឋានជាអនីតិសង្វាស ។

៤.២.កំណត់យកឪពុកឈ្មោះ [redacted] ឈៀង ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សូលីន ភេទប្រុស កើតថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០០២ មានសំបុត្របញ្ជាក់កំណើតលេខ ៣៨ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រង់ ។

៤.៣.កំណត់យកម្ដាយឈ្មោះ [redacted] អូន ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សៀវមិញ ភេទស្រី កើតថ្ងៃទី [redacted] មានសំបុត្រកំណើតលេខ ៥៨ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្រង់ ។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

៤.៤.-តាមការអះអាងរបស់គូភាគី បានព្រមព្រៀងគ្នាបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម ៖

ក. តុចំនួន ៣៥តុ, មានចានចង្កឹះចំនួន ៣៥០, ស្លាបព្រាចំនួន ៣៥០, កែវចំនួន ៣៥០, វែកបាយចំនួន ១០, វែកសម្លរចំនួន ១០, ថាសដាក់ល្បោយចំនួន ១០, ថាសលើកម្ហូបចំនួន ១០, ចានគ្រោងចំនួន ៣០, ចានញាំចំនួន ៣៥, ចានពងក្រពើចំនួន ៧០, ចានគ្រឿងក្លែមចំនួន ១៧៥, ចានទ្រនាប់ចំនួន ៣៥០, ឆ្នាំងបាយចំនួន ១០, ខ្ទះលេខ៨៥០ចំនួន ៦, កាធុនតូច និងធំចំនួន ២៥, តុរិលចំនួន ៣៥, ឆ្នាំងភ្លើងចំនួន ៣៥, ស្រោមកៅអី ៣៥០, រនាំងបាំងឡប់ឡែពាក់កណ្ដាល ម្នាក់រាប់ជាក់ស្ដែង, ធុងទឹកកកឱ្យអា២០០លីត្រចំនួន ០២, ឱ្យទៅដើមចោទ ។

ខ. ពោង ០៤ខ្នង ឱ្យទៅដើមចោទ

គ. ធុងបាស់ ០១ឈុត ចែកជាពីរ

ឃ. មេក្រូចំនួន ០៤ ចែកជាពីរ

ង. ម៉ាស៊ីនភ្លើងមានចំនួន ០២ ចែកគ្នាម្នាក់មួយ ។

ច. សុំឱ្យដើមចោទប្រគល់កាតគ្រីឡានចំនួន ០២ និងពែកមីឡានខ្ញុំ ០១ និងកាតគ្រីម៉ូតូ ០១ ។ ហេតុនេះគប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ។

៤.៥.ឲ្យភាគីដើមចោទ ចុងចម្លើយទទួលបន្ទុកអាហារកិច្ចតាមលទ្ធភាព ។

៤.៦.ចំពោះបំណុលរួមមានប្រាក់ខ្ចីធនាគារ[redacted]ចំនួន ២៣,៤០០ (ពីរម៉ឺនបីពាន់បួនរយ) ដុល្លាររួមទាំងអត្រាការប្រាក់ ឲ្យភាគីដើមចោទ ចុងចម្លើយទទួលបន្ទុកលើបំណុលរួមនេះម្នាក់ពាក់កណ្តាល ។

៤.៧.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី ម្នាក់ពាក់កណ្តាល ។

សាលក្រមនេះប្រកាសនៅសាលសវនាជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ នៅចំពោះមុខដើមចោទ និង ចុងចម្លើយ និងបើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

អនុសារសាលក្រមនេះមានអានុភាពដូចមូលសាលក្រមដែរ

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]